# ការរីកចម្រើនខាងគុណសម្បត្តិ មាន ៤០ ប្រការ

មណ្ឌលសាវជ្រាវបានបញ្ជាក់កត្តាទាំងឡាយ នៃអភិវឌ្ឍនវិជ្ជមាន ដែលជាជំនួយ ដល់យុវជន-យុវនារី រស់នៅ ដោយសុភមង្គល ឧត្តមគតិ និង ភាពជាអ្នកទទួលខុសត្រូវ ។

## គុណសម្បត្តិខាងក្រៅ

| ប្រភេទ | ឈ្មោះគុណសម្បត្តិ និយមន័យ |
|---|---|
| ការទំនុកបម្រុង | ១. ការទំនុកបម្រុងរបស់គ្រួសារ-ភារៈជាគ្រួសារ តែងផ្តល់ នូវការស្រឡាញ់និងឧបត្ថម្ភកម្រិតខ្ពស់ |
| | ២. ការសន្ទនាជាវិជ្ជមានក្នុងគ្រួសារ-យុវវ័យនិងឪពុកម្តាយរបស់គេ តែងនិយាយស្តីរាប់អានិងគ្នា ហើយយុវវ័យ មានបំណងសូមដំបូន្មាននិងដំណោះស្រាយ រំពីឪពុកម្តាយ ។ |
| | ៣. ទំនាក់ទំនងនិងមនុស្សពេញវ័យដទៃទៀត-យុវវ័យ តែងមានការឧបត្ថម្ភ អំពីមនុស្សពេញ<br>វ័យ ពីពនាក់ឡើងទៅ ក្រៅពីឪពុកម្តាយរបស់ខ្លួន ។ |
| | ៤. ភាពជិតស្និទនិងញាតិជិតខាង-យុវវ័យតែងមានអារម្មណ៍យកចិត្តទុកដាក់និងអ្នកជិតខាងទាំឡាយ |
| | ៥. ការយកចិត្តទុកដាក់និងសាលារៀន-សាលាតែងផ្តល់ នូវបរិយាកាសស្និទស្នាល និងការដាស់តឿន |
| | ៦. សហការរបស់មាតាបិតា ក្នុងការសិក្សា-ឪពុកម្តាយទាំងឡាយតែងជាអ្នកចូលរួមយ៉ាងសកម្ម ក្នុងការជួយយុវវ័យ ឲ្យបានសម្រេចការសិក្សារៀនសូត្រ ។ |
| ការប្រគល់អំណាច | ៧. សហគមន៍ឲ្យតម្លៃដល់យុវវ័យ-យុវវ័យតែងមានអារម្មណ៍ថា មនុស្សពេញវ័យក្នុងសហគមន៍នោះ ឲ្យតម្លៃដល់ពួកគេ ។ |
| | ៨. យុវវ័យគឺជាប្រភពបន្តវេន-យុវវ័យទាំងឡាយ ត្រូវគេប្រគល់ ភារៈកិច្ចដ៏មានប្រយោជន៍នៅក្នុង<br>សហគមន៍នោះ ។ |
| | ៩. បម្រើសេវាដល់អ្នកដទៃ-យុវវ័យបម្រើការក្នុងសហគមន៍១ម៉ោងយ៉ាងតិច ក្នុងមួយសប្តាហ៍ ។ |
| | ១០. សុវត្ថិភាព-យុវវ័យតែងមានសុវត្ថិភាពនៅក្នុងផ្ទះ សាលារៀន និងក្នុងសហគមន៍ ។ |
| ព្រំដែន/សេចក្តីសង្ឃឹម | ១១. ព្រំដែនទាំងឡាយរបស់គ្រួសារ-គ្រួសារមានបទវិន័យយ៉ាងច្បាស់លាស់និងការវិនិច្ឆ័យ និងការតាមដាន តើយុវវ័យទាំងនោះនៅទីកន្លែងណា ។ |
| | ១២. កម្រិតព្រំដែននៅសាលារៀន-សាលារៀនតែងផ្តល់ នូវវិន័យយ៉ាងច្បាស់លាស់និងផលវិបាក ។ |
| | ១៣. កម្រិតព្រំដែនរបស់សហគមន៍-ញាតិសន្តានមានការទទួលខុសត្រូវចំពោះអាកប្បកិរិយារបស់យុវវ័យ ។ |

**ទ្រព្យសម្បត្តិខាងក្នុង**

១៤. មនុស្សពេញវ័យជាគម្រូ-ឪពុកម្តាយនិងមនុស្សដទៃទៀត តែងធ្វើជាគម្រូល្អ អាកប្បកិរិយា ប្រកបទៅដោយជំហរទទួលខុសត្រូវ ។

១៥. ការដឹកនាំផ្លូវល្អរបស់មិត្រភក្តិ-កល្យាណមិត្រទាំងឡាយរបស់យុវវ័យ តែងបានជាគម្រូ គម្រូខាងជំហរទទួលខុសត្រូវ ។

១៦. ការសង្ឃឹមកម្រិតខ្ពស់-ឪពុកម្តាយនិងគ្រូបង្រៀនទាំងឡាយ តែងជួយដាស់តឿន យុវវ័យទាំងនោះ ឲ្យធ្វើកិច្ចការបានល្អ ។

**ការចំណាយពេលវេលាមានប្រយោជន៍**

១៧. សកម្មភាពច្នៃប្រឌិតទាំងឡាយ-យុវវ័យ ចំណាយយ៉ាងតិចបីម៉ោង ក្នុងមួយសប្តាហ៍ ក្នុងការសិក្សាឬក៏ហាត់ភ្លេង ល្ខោន ឬក៏សិល្បៈទាំងឡាយដទៃណាមួយ ។

១៨. កម្មវិធីសម្រាប់យុវវ័យ- យុវវ័យ ចំណាយយ៉ាងតិចបីម៉ោង ក្នុងមួយសប្តាហ៍ ក្នុងការលេងកីឡា ចូលជាសមាគម ឬក៏អង្គការទាំងឡាយ នៅសាលាឬក៏ នៅក្នុងសហគមន៍របស់ខ្លួន ។

១៩. ជំនឿសាសនាក្នុងសហគមន៍-យុវវ័យ ចំណាយយ៉ាងតិចមួយម៉ោង ក្នុងមួយសប្តាហ៍ នៅក្នុងសកម្មភាពទាំងឡាយ នៃសាសនាណាមួយ ។

២០. ពេលវេលានៅផ្ទះ-យុវវ័យ តែងទៅលេងជាមួយមិត្រភក្តិ ដោយមិនមានកិច្ចការអ្វីត្រូវធ្វើ ពី២ ទៅបីយប់ ក្នុងមួយសប្តាហ៍ ។

---

**ការតាំងចិត្តសិក្សា**

២១.សេចក្តីប៉ងប្រាថ្នាយកឈ្នះលើការសិក្សា-យុវវ័យ តែងមានបំណងធ្វើកិច្ចការសាលាឲ្យបានល្អ នៅសាលារៀន ។

២២. សកម្មការងារក្នុងថ្នាក់-យុវវ័យ ត្រូវគេរំពឹងឲ្យចូលរួមយ៉ាងសកម្ម ក្នុងការរៀនសូត្រ

២៣. កិច្ចការសាលា-យុវវ័យរាយការណ៍ថាធ្វើកិច្ចការសាលារៀនយ៉ាងតិច១ម៉ោង ក្នុងពេលវេលាសិក្សា

២៤. ផ្តោតអារម្មណ៍លើសាលារៀន-យុវវ័យតែងយកចិត្តទុកដាក់និងសាលារបស់នាង

២៥. អានដើម្បីការកំសាន្ត-យុវវ័យអាន សម្រាប់ការកំសាន្តរបស់ខ្លួនពី៣ម៉ោងឡើងទៅក្នុងមួយសប្តាហ៍

**គុណតម្លៃវិជ្ជមាន**

២៦. ការយកចិត្តទុកដាក់-យុវវ័យឲ្យតម្លៃយ៉ាងខ្ពស់ ក្នុងការជួយមនុស្សដទៃ

២៧. សមភាពនិងយុត្តិធម៌-យុវវ័យឲ្យតម្លៃខ្ពស់លើការគាំទ្រឲ្យមានសមភាពនិងបន្ថយភាពអត់ឃ្លាននិងភាពក្រីក្រ

២៨. គោលជំហររឹងប៉ឹង-យុវវ័យធ្វើអំពីខុសឆ្គងអ្វីមួយ ហើយតវ៉ាពន្យល់អំពីជំនឿរបស់ខ្លួន

២៩. ភាពស្មោះត្រង់-យុវវ័យតែងប្រាប់ការពិត បើទោះបីជាការនោះពិបាកនឹងធ្វើក៏ដោយ

៣០. ភាពទទួលខុសត្រូវ-យុវវ័យនឹងទទួលយកនិងទទួលខុសត្រូវផ្ទាល់ខ្លួន

៣១. ការវៀរចាក-យុវវ័យមានជំនឿថា ជាការប្រសើរមួយ វៀរចាកការសេពកាមឬស្រាឬគ្រឿងញៀនដទៃណាមួយ

**សមត្ថភាពខាងសង្គម**

៣២.គម្រោងការនិងការសម្រេចចិត្ត- យុវវ័យចេះរៀបចំផែនការជាមុន ហើយធ្វើការ

សម្រេចទាំងឡាយរបស់គេ

៣៣. សមត្ថភាពនៃការទាក់ទងមនុស្ស-យុវវ័យមានជំនាញការខាងការយល់ទឹកចិត្ត ចាប់អារម្មណ៍ទាន់ពេលវេលានិងមិត្តភាព

៣៤. សមត្ថភាពខាងប្រពៃណី- យុវវ័យ មានចំណេះនិងងាយស្រួលទាក់ទងជាមួយ មនុស្ស ដែលមានប្រភពដើម នៃប្រពៃណី ពណ៌សម្បុរ សញ្ជាតិផ្សេងគ្នា

៣៥. ជំនាញការខាងការ ការពារខ្លួន-យុវវ័យ អាចប្រឆាំងនឹងការគាបសង្កត់របស់មិត្តរួម ជំនាន់ និងសភាពការណ៍ណា ដែលបណ្តាលឲ្យមានគ្រោះថ្នាក់

៣៦. ការដោះស្រាយដោយបញ្ហាដោយសន្តិវិធី-យុវវ័យ តែងស្វែងរកដំណោះស្រាយគ្រប់ បញ្ហា ដោយមិនប្រើអំពើហិង្សា

៣៧. អំណាចផ្ទាល់ខ្លួន-យុវវ័យ មានអំណាចលើ "អ្វីៗ ដែលមានចំពោះខ្ញុំ"

៣៨. ជំនឿទុកចិត្តលើខ្លួនឯង-យុវវ័យ តែងប្រាប់គេថា ខ្លួនមានជំនឿយ៉ាងកក់ក្តៅលើខ្លួន ឯង

៣៩. ជីវិតមានគោលដៅ-យុវវ័យតែងរាយការណ៍ថា "ជីវិតខ្ញុំ មានទិសដៅពិតប្រាកដ"

៤០. ទស្សនៈវិជ្ជមាន សម្រាប់អនាគតរបស់ខ្លួន-យុវវ័យ មានសុទិដ្ឋិ: អំពីអនាគតរបស់ខ្លួន